គោរពជូនសហការី សមាជិកក្រុមប្រឹក្សាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់

យើងមានមោទនភាពជាខ្លាំង ក្នុងការប្រកាសលោកសាស្រ្តាចារ្យ ដាន់ឃឹន ម៉ាកខាហ្គោ (Duncan McCargo) ជាសមាជិកក្រុមប្រឹក្សាភិបាលផ្នែកសិក្សាធិការរបស់អង្គការវេទិកាអនាគត។

លោក ដាន់ឃឹន ជាសាស្រ្តាចារ្យវិទ្យាសាស្រ្តនយោបាយនៅសកលវិទ្យាល័យលីដ (University of Leeds) ប្រទេសអង់គ្លេស និងជាសាស្រ្តាចារ្យវិទ្យាសាស្រ្តនយោបាយ នៅសកលវិទ្យាល័យកូឡុំបៀរ (Columbia University) នៅទីក្រុងញូយ៉ក។ គាត់ទំនងជាត្រូវបានគេស្គាល់ខ្លាំង បន្ទាប់ពីបានស្រាវជ្រាវនិងសរសេរសៀវភៅជាច្រើនអំពីនយោបាយប្រទេសថៃសម័យទំនើប ដោយបានផ្តោតចំបងទៅលើធម្មជាតិនៃអំណាចរបស់ប្រទេសនេះ។

លោក ម៉ាកខាហ្គោ បានចំណាយពេលជាច្រើនឆ្នាំនៅប្រទេសថៃ គាត់ក៏ធ្លាប់បានរស់នៅប្រទេសសឹង្ហបុរី និងបង្រៀននៅប្រទេសកម្ពុជានិងជប៉ុន និងបានបោះពុម្ពស្នាដៃអំពីប្រទេសឥណ្ឌូនេស៊ី និងវៀតណាមផងដែរ។ សៀវភៅទីប្រាំបួនរបស់លោក ម៉ាកខាហ្គោ «ការហែកទឹកដីជាចំណែក៖ ឥស្លាម និងធម្មនុញ្ញភាព នៅភាគខាងត្បូងប្រទេសថៃ» បានឈ្នះពានរង្វាន់សៀវភៅ Bernard Schwartz Book Prize របស់សមាគមអាស៊ី។ គាត់ក៏ធ្លាប់ធ្វើជាអ្នកស្រាវជ្រាវរយៈពេលខ្លីនៅមជ្ឈមណ្ឌលខេមរសិក្សា នៅរាជធានីភ្នំពេញ ចន្លោះឆ្នាំ២០០៤ និង ២០០៥ ដោយបានសរសេរអត្ថបទមួយចំនួនអំពីនយោបាយប្រទេសកម្ពុជាផងដែរ។

អង្គការវេទិកាអនាគត ចាត់ទុកបទពិសោធន៍កម្រិតតំបន់ និង គុណវុឌ្ឍផ្នែកសិក្សាធិការ យ៉ាងទូលំទូលាយរបស់លោក ដាន់ឃឹន ជាវិភាគទានដ៏មានអត្ថប្រយោជន៍ សម្រាប់កម្មវិធី និងបេសកកម្មរបស់ពួកយើង។

សូមអរគុណ

អ៊ូ វិរៈ
ស្ថាបនិក និងប្រធាន